ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៣ សជស

# សារលិខិត
## របស់
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសខួបអនុស្សាវរីយ៍ លើកទី១៣៤ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២០

***បងប្អូន ក្មួយៗ កម្មករនិយោជិត និយោជក និងជនរួមជាតិទាំងអស់ជាទីស្នេហា!***

តាងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានចូលរួមជាមួយបងប្អូន ក្មួយៗ កម្មករនិយោជិត និយោជក និងជនរួមជាតិទាំងអស់ ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី១៣៤ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា ក្រោមប្រធានបទ "**សន្តិភាព និងការងារសមរម្យ**"។ ប្រធានបទនេះ ពិតជាមានអត្ថន័យយ៉ាងជ្រាលជ្រៅ និងមានតម្លៃជាសារវន្តជាសកល និងជាពិសេសសម្រាប់ព្រះរាជាណាចក្រកម្ពុជា ដែលធ្លាប់ទទួលការញាំញីដោយសង្គ្រាមបំផ្លិចបំផ្លាញខ្ទេចខ្ទាំរាប់សតវត្ស ពីព្រោះមានតែការរក្សាបាននូវសន្តិភាពទេ ទើបមានការអភិវឌ្ឍ និងការបង្កើតការងារសមរម្យ។

ទិវាពលកម្មអន្តរជាតិថ្ងៃទី១ ខែឧសភា នៅព្រះរាជាណាចក្រកម្ពុជាយើង ត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំចាប់តាំងពីថ្ងៃរំដោះពីរបបប្រល័យពូជសាសន៍ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រហូតមកដល់បច្ចុប្បន្ន។ ទោះបីឆ្នាំនេះប្រទេសជាតិយើង និងពិភពលោកទាំងមូលកំពុងប្រឈមនឹងជំងឺកូវីដ-១៩ ក៏រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តឱ្យមានការរៀបចំរំលឹកនូវទិវាដ៏មានសារៈសំខាន់ជាប្រវត្តិសាស្ត្រនេះ។

ដោយសារតែរាជរដ្ឋាភិបាលអាចបន្តរក្សា និងការពារបានយ៉ាងរឹងមាំនូវសន្តិភាព ស្ថិរភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ទើបប្រទេសជាតិយើងទទួលបាននូវការអភិវឌ្ឍលើគ្រប់វិស័យ។ ដើម្បីឱ្យកម្ពុជាយើងអាចសម្រេចបានតាមមហិច្ឆតាប្រែក្លាយពីប្រទេសដែលមានចំណូលមធ្យមកំរិតទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកំរិតខ្ពស់នាឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នាឆ្នាំ២០៥០ រាជរដ្ឋាភិបាលបាននិងកំពុងខិតខំជំរុញការអនុវត្តដោយបានជោគជ័យនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ រួមទាំងគោលនយោបាយអាទិភាពសំខាន់ៗ ដើម្បីបង្កើនល្បឿនការអភិវឌ្ឍ និងបង្កើតការងារសមរម្យជូនប្រជាពលរដ្ឋ ក្នុងនោះរួមមានៈ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មនៅកម្ពុជា ឆ្នាំ២០១៥-២០២៥ គោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥ គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះ

បណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ និងអនុវត្តនូវការកែទម្រង់មុតស្រួច ក្រោមអភិក្រម **"ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់"** និងបាវចនា **"កែទម្រង់ផ្ទៃក្នុង និងបង្កើនមិត្តខាងក្រៅក្នុងស្មារតីឯករាជ្យ"**។ ជាលទ្ធផល យើងបន្តសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រាជាង ៧% ជាមធ្យមក្នុងមួយឆ្នាំ ដែលបានបង្កើតការងារកាន់តែច្រើន និងប្រសើរឡើងជូនប្រជាពលរដ្ឋ ជាពិសេសយុវជន។ ជាក់ស្ដែង រាជរដ្ឋាភិបាលអាចធានាបាននូវអត្រាមានការងារធ្វើ ៩៩,៧% នៃកម្លាំងពលកម្មសរុប ១០លាននាក់ នៅក្នុងនោះ រួមមាន ក្នុងប្រទេសប្រមាណ ៣,៦៩លាននាក់ (ផ្នែកសេដ្ឋកិច្ចក្នុងប្រព័ន្ធចំនួនជាង ១,៥លាននាក់ និងផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធប្រមាណ ២,២លាននាក់) វិស័យកសិកម្មប្រមាណ ៤លាននាក់ មន្ត្រីសាធារណៈចំនួន ៥០ម៉ឺននាក់ និងពលករដែលធ្វើការនៅក្រៅប្រទេស ចំនួនប្រមាណជាង ១,២៨លាននាក់។

កន្លងទៅនេះ ដើម្បីជំរុញការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍវិស័យឧស្សាហកម្ម ខ្ញុំផ្ទាល់បានចុះជួបជាមួយបងប្អូនកម្មករនិយោជិត គិតចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩ បានចំនួន ៧៧លើក សរុបកម្មករនិយោជិតចំនួនប្រមាណជិត ១លាននាក់ ដែលតាមរយៈនេះ បានរកឃើញបញ្ហា និងដាក់ចេញនូវគោលការណ៍ និងវិធានការជាច្រើន ជាពិសេសអនុសាសន៍១០ចំណុច ដើម្បីលើកកម្ពស់ជីវភាព សុខុមាលភាពកម្មករនិយោជិត និងទំនាក់ទំនងវិជ្ជាជីវៈ ហើយខ្ញុំនឹងបន្តសកម្មភាពនេះជារៀងរហូតនៅក្នុងតំណែងរបស់ខ្ញុំជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

រាជរដ្ឋាភិបាលបានបន្តលើកកម្ពស់ការការពារសិទ្ធិ សេរីភាពអង្គការវិជ្ជាជីវៈ ថែរក្សាសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ ផ្តល់អត្ថប្រយោជន៍នានាជូនដល់បងប្អូនកម្មករនិយោជិត រួមទាំងការផ្តល់កិច្ចគាំពារសង្គមផងដែរ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ស្តីពីការងារ និងអនុសញ្ញាអន្តរជាតិខាងការងារទាំង១៣ ដែលកម្ពុជាបានផ្តល់សច្ចាប័ន តាមរយៈយន្តការត្រីភាគីសម្រាប់សំរាទសង្គម ជាអាទិ៍ក្រុមប្រឹក្សាអាជ្ញាកណ្តាល គណៈកម្មការប្រឹក្សាការងារ ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា រួមទាំងយន្តការត្រីភាគីបូកជាច្រើនទៀត។ ការបើកចំហរសេរីភាពអង្គការវិជ្ជាជីវៈបានធ្វើឱ្យកំណើននៃការចុះបញ្ជីកើនឡើងគួរឱ្យកត់សំគាល់ គិតត្រឹមឆ្នាំ២០១៩ មានអង្គការវិជ្ជាជីវៈចំនួន ៥ ២៥៦ កំពុងប្រតិបត្តិការ ក្នុងនោះសហជីពមូលដ្ឋានមានចំនួន ៤ ៩៩៦ សហព័ន្ធសហជីពមានចំនួន ២១៦ សហភាពសហជីពមានចំនួន ៣៣ និងសមាគមនិយោជកមានចំនួន ១១។

រាជរដ្ឋាភិបាលបានបន្តយកចិត្តទុកដាក់ក្នុងការលើកកម្ពស់សុវត្ថិភាព និងសុខភាពការងាររបស់កម្មករនិយោជិត នៅតាមគ្រប់រោងចក្រ សហគ្រាស មានគិលានដ្ឋាន កន្លែងហូបបាយ បន្ទប់បំបៅកូន និងទារកដ្ឋានដែលបានជួយធ្វើឱ្យកាន់តែប្រសើរឡើងនូវសុខុមាលភាពរបស់កម្មករនិយោជិត។ កម្មវិធីបង្ការគ្រោះថ្នាក់ការងារ និងបង្កើនសុវត្ថិភាពក្នុងការដឹកជញ្ជូន និងការធ្វើដំណើររបស់កម្មករនិយោជិត ត្រូវបានជំរុញអនុវត្តយ៉ាងសកម្ម។ ក្នុងពេលថ្មីៗនេះ ជាមួយនឹងការលេចឡើងនូវជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរដែលបណ្តាលមកពីជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលបាននិងកំពុងចាត់វិធានការហ្មត់ចត់ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ចំពោះសុខភាពរបស់ប្រជាពលរដ្ឋ រួមទាំងការណែនាំដល់កម្មករនិយោជិត និងនិយោជកទាំងអស់ឱ្យប្រកាន់ខ្ជាប់នូវការរក្សាអនាម័យល្អផ្ទាល់ខ្លួន និងនៅកន្លែងធ្វើការ អនុលោមតាមការណែនាំរបស់ក្រសួងសុខាភិបាល និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបង្ការទប់ស្កាត់ការឆ្លងរាលដាលជំងឺនេះ។

រាជរដ្ឋាភិបាលបានបន្តយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍរបបសន្តិសុខសង្គម ដើម្បីពង្រីកវិសាលភាពកាន់តែទូលំទូលាយ គ្របដណ្តប់បួនផ្នែករួមមាន ផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារ សំដៅធានាសង្គតិភាពនិងសមធម៌ រវាងមន្ត្រីរាជការសាធារណៈ និងកម្មករនិយោជិត តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម និងការរៀបចំដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងរបបសោធនសម្រាប់កម្មករនិយោជិតនៅក្នុងឆ្នាំ២០២០។ ដើម្បីផ្តល់នូវកិច្ចគាំពារសង្គមជូនបងប្អូនកម្មករនិយោជិត បេឡាជាតិសន្តិសុខសង្គមបានផ្តល់នូវរបបហានិភ័យការងារ និងថែទាំសុខភាពចាប់តាំងពីឆ្នាំ២០០៨ ដែលមានសហគ្រាស គ្រឹះស្ថាន

ជាង ១ម៉ឺន៤ពាន់ ជាសមាជិក ដោយមានកម្មករនិយោជិតទាំងក្នុងនិងក្រៅប្រព័ន្ធ និងមន្ត្រីសាធារណៈ សរុបប្រមាណជាង ២លាន១សែននាក់ កំពុងទទួលបានអត្ថប្រយោជន៍ពីរបបទាំងនេះ។ បន្ថែមពីនេះ ចាប់ពីឆ្នាំ២០១៨មក រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយឧបត្ថម្ភសាច់ប្រាក់ដល់កម្មការិនីទាំងក្នុងនិងក្រៅប្រព័ន្ធ និងមន្ត្រីសាធារណៈ នៅពេលសម្រាលកូន ដែលមកដល់ពេលនេះមានកម្មការិនីសរុបប្រមាណ ២សែននាក់សរុបទឹកប្រាក់ប្រមាណ ២០លានដុល្លារ។

រាជរដ្ឋាភិបាល បាននិងកំពុងបន្តកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយដៃគូអន្តរជាតិនានា មានជាអាទិ៍ គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO-BFC) គម្រោងពង្រឹងនិរន្តរភាពវិស័យវាយនភណ្ឌ និងកាត់ដេរនៅទ្វីបអាស៊ី គម្រោងគំនិតផ្តួចផ្តើមកិច្ចព្រមព្រៀងសកល និងកម្មវិធីការងារសមរម្យប្រចាំប្រទេសកម្ពុជា និងគម្រោងនានាជាមួយដៃគូជាច្រើនទៀត។

***បងប្អូន ក្មួយៗ កម្មករនិយោជិត និយោជក និងជនរួមជាតិទាំងអស់ជាទីស្នេហា!***

ជាមួយវឌ្ឍនភាពខាងលើ ការលេចឡើងនូវជំងឺកូវីដ-១៩ នាពេលថ្មីៗនេះ បានបង្កជាបញ្ហាប្រឈមដ៏ធំមួយទៀត បន្ថែមលើបញ្ហាដែលមានស្រាប់ ជាពិសេសគឺសង្គ្រាមពាណិជ្ជកម្ម និងការថមថយកំណើនសេដ្ឋកិច្ច សម្រាប់សកលលោកក៏ដូចជាកម្ពុជាយើង។ ដើម្បីកាត់បន្ថយផលប៉ះពាល់ រក្សាលំនឹងអាជីវកម្ម និងលំនឹងជីវភាពជូនក្មួយៗកម្មករនិយោជិតទាំងអស់ រាជរដ្ឋាភិបាលបានដាក់ចេញវិធានការអន្តរាគមន៍បន្ទាន់ជុំទីមួយ ដល់វិស័យដែលទទួលរងផលប៉ះពាល់ធ្ងន់ជាងគេ គឺវិស័យអាជីវកម្មទេសចរណ៍នៅក្នុងខេត្តសៀមរាប និងវិស័យកាត់ដេរសំលៀកបំពាក់ ស្បែកជើង និងកាបូប។ តាមរយៈវិធានការនេះ សណ្ឋាគារនិងផ្ទះសំណាក់ក្នុងខេត្តសៀមរាបនឹងទទួលបានការលើកលែងការបង់ពន្ធប្រចាំខែរយៈពេល៤ខែ ព្រមទាំងការអនុគ្រោះមួយចំនួនទៀត រីឯក្មួយៗកម្មករនិយោជិតបម្រើការតាមសណ្ឋាគារ ផ្ទះសំណាក់ និងភ្នាក់ងារទេសចរណ៍ដែលបាត់បង់ការងារនឹងទទួលបាននូវវគ្គបណ្តុះបណ្តាលដែលរៀបចំដោយក្រសួងទេសចរណ៍ នៃមុខវិជ្ជាចំណេះដឹងថ្មីឬការបង្កើនចំណេះដឹងបន្ថែម និងការផ្តល់នូវប្រាក់ខែសមរម្យ។ ចំពោះវិស័យវាយនភណ្ឌកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប សហគ្រាស គ្រឹះស្ថានដែលទទួលរងផលប៉ះពាល់ពីការខ្វះវត្ថុធាតុដើម និងការព្យួរភាពអនុគ្រោះពន្ធលើទំនិញមួយចំនួននៅក្រោមកម្មវិធី EBA នឹងទទួលការផ្តល់ការលើកលែងពន្ធ (Tax Holiday) រយៈពេលពី ៦ខែ ដល់១ឆ្នាំ ទៅតាមកម្រិតធ្ងន់ធ្ងរនៃផលប៉ះពាល់ជាក់ស្តែង។ ក្នុងករណីព្យួរកិច្ចសន្យាការងារដោយសារខ្វះវត្ថុធាតុដើម សហគ្រាស គ្រឹះស្ថាននឹងត្រូវបានអនុញ្ញាតលើការមិនបង់ប្រាក់វិភាគទានធានារ៉ាប់រងហានិភ័យការងារ និងថែទាំសុខភាព ក្នុងអំឡុងពេលព្យួរ ប៉ុន្តែត្រូវផ្តល់ប្រាក់ឧបត្ថម្ភចំនួន៤០% នៃប្រាក់ឈ្នួលអប្បបរមា (ដែលមានចំនួន ១៩០ ដុល្លារអាម៉េរិកសម្រាប់ឆ្នាំ២០២០) ដល់ក្មួយៗកម្មករនិយោជិត ខណៈរាជរដ្ឋាភិបាលនឹងរួមចំណែកបន្ថែម ២០% នៃប្រាក់ឈ្នួលអប្បបរមា ១៩០ដុល្លារអាម៉េរិកនេះ ដល់កម្មករនិយោជិត ដែលបានចូលរួមវគ្គបណ្តុះបណ្តាលជំនាញទន់ដែលរៀបចំដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅតាមបណ្តាសហគ្រាស គ្រឹះស្ថាន។ ក្នុងករណីសហគ្រាស គ្រឹះស្ថានបិទលែងដំណើរការ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងផ្តល់អន្តរាគមន៍ជួយដល់ក្មួយៗកម្មករនិយោជិត ដែលបាត់បង់ការងារ និងមិនទាន់អាចរកការងារថ្មីបានឬចង់ផ្លាស់ប្តូរការងារនាពេលអនាគត តាមរយៈវិធានការជួយរកការងារឱ្យធ្វើបានឆាប់រហ័ស ផ្តល់ការបណ្តុះបណ្តាលជំនាញទន់ និងផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេសថ្មីរយៈពេល៤ខែ ដើម្បីរកការងារធ្វើក្នុងវិស័យមិនមែនកាត់ដេរ និងផ្តល់ជូនសិក្ខាកាមនូវប្រាក់ឧបត្ថម្ភចំនួន ១២០ដុល្លារអាម៉េរិកក្នុងមួយខែ សម្រាប់រយៈពេលបណ្តុះបណ្តាល៤ខែ និងរយៈពេលរកការងារធ្វើមិនទាន់បាន២ខែ។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវវិធានការទូទៅសម្រាប់ជួយដល់ក្មួយៗកម្មករនិយោជិតដែលទទួលរងផលប៉ះពាល់រួមមាន៖ ការលើកលែងពន្ធប្រថាប់ត្រាចំពោះការទិញផ្ទះតម្លៃក្រោម៧ម៉ឺនដុល្លារអាម៉េរិក ការស្នើឱ្យក្រុមហ៊ុនអភិវឌ្ឍលំនៅដ្ឋានពន្យារពេលការបង់រំលស់ និងអគ្គិសនីកម្ពុជា និងរដ្ឋាករទឹក

អនុញ្ញាតឱ្យកម្មករនិយោជិតជំពាក់ការបង់ថ្លៃសេវាប្រើប្រាស់ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ ព្រមទាំង គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុធ្វើការបន្ធូរបន្ថយការប្រាក់ និងពន្យារពេលការសងប្រាក់ដើម។ លើសពីនេះ រាជរដ្ឋាភិបាលក៏បានត្រៀមដាក់ចេញនូវវិធានការថ្មីៗបន្ថែមទៀត ក្នុងករណីដែលស្ថានភាពសេដ្ឋកិច្ចរងផលប៉ះពាល់កាន់តែធ្ងន់ធ្ងរ។

នាឱកាសនេះ រាជរដ្ឋាភិបាលសូមបន្តអំពាវនាវជាថ្មីម្តងទៀតដល់ម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថាន និងបងប្អូនកម្មករនិយោជិតទាំងអស់ សូមចូលរួមអនុវត្តឱ្យបានហ្មត់ចត់បំផុតនូវវិធានការបង្ការ និងទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ ឱ្យបានត្រឹមត្រូវទៅតាមការណែនាំរបស់ក្រសួងសុខាភិបាល និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈការអនុវត្តនូវវិធានការសុវត្ថិភាព និងសុខភាពការងារជូនបងប្អូនកម្មករនិយោជិត។ រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងមុតមាំថា គ្រប់ម្ចាស់ នាយករោងចក្រ សហគ្រាស គ្រឹះស្ថាន និងបងប្អូនកម្មករនិយោជិតទាំងអស់ នឹងចូលរួមទប់ស្កាត់និងប្រឆាំងជំងឺរាលដាលផ្លូវដង្ហើមធ្ងន់ធ្ងរ កូវីដ-១៩ ដើម្បីសេចក្តីសុខសាន្តយើងទាំងអស់គ្នា ដើម្បីអនាគតការងារយើង សង្គមជាតិយើង និងសេដ្ឋកិច្ចជាតិយើង។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់បងប្អូនជនរួមជាតិដែលកំពុងធ្វើការទាំងក្នុង និងក្រៅប្រទេស ក៏ដូចជាអស់លោក លោកស្រី ជានិយោជក និងនិយោជិតបរទេស ជាមន្ត្រីអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ដែលកំពុងស្នាក់នៅ និងបំពេញភារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រកបដោយពុទ្ធពរ និងពរទាំងប្រាំប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ** កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ អង្គារ ១៥ កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ មេសា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**